**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
## ស្តីពី
## ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា និងទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២០

នាព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ វេលាម៉ោង៨: ០០ នាទី នៅសាលសិក្ខាសាលាខាង-ជើង វិមានរដ្ឋចំការមន បានបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមករា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្រោមអធិបតីភាព **ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា** ដោយមានការអញ្ជើញចូលរួមពីថ្នាក់អនុប្រធាននាយកដ្ឋានឡើងចំនួន១០៦នាក់។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមអគ្គលេខាធិការ** បានសម្តែងនូវកិច្ចស្វាគមន៍ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលមានវត្តមានក្នុងអង្គប្រជុំ និងបានជម្រាបជូនអង្គប្រជុំអំពីរបៀបវារៈថ្មីសម្រាប់កិច្ចប្រជុំបូកសរុបចាប់ពីខែមករា ឆ្នាំ២០២០ នេះតទៅ។ ការប្រជុំបូកសរុបប្រចាំខែមានចំនួន ០២លើក។ ការប្រជុំលើកទី១ ធ្វើឡើងនាបំណាច់ខែនីមួយៗ និងការប្រជុំលើកទី២ ធ្វើនៅពាក់កណ្តាលនៃខែនីមួយៗជាមួយថ្នាក់ដឹកនាំចាប់ពីប្រធាន និងអនុប្រធានការិយាល័យ។ ចំពោះការប្រជុំបូកសរុបប្រចាំខែ ត្រូវមានប្រធាននាយកដ្ឋាន ០៣រូប និងការប្រជុំពាក់កណ្តាលខែ ត្រូវមានប្រធានការិយាល័យ ០៣រូប មកពីអគ្គនាយកដ្ឋានទាំង៣ ឡើងរាយការណ៍អំពីលទ្ធផលការងាររបស់នាយកដ្ឋាន និងការិយាល័យរបស់ខ្លួនដែលសម្រេចបានក្នុងខែកន្លងទៅ និងលើកទិសដៅការងារសម្រាប់ខែបន្ទាប់ ឬក៏បញ្ហាប្រឈមផ្សេងៗ ដើម្បីឱ្យអង្គប្រជុំជ្រាប និងរកដំណោះស្រាយក្នុងការអនុវត្តការងារឱ្យរលូនទៅមុខៗ។ លើសពីនេះទៀតគឺ ដើម្បីដកស្រង់បទពិសោធន៍ការងារ និងពង្រឹងសមត្ថភាពការដឹកនាំគ្រប់គ្រងតាមអង្គភាពនីមួយៗឱ្យកាន់តែល្អប្រសើរ។

ជាកិច្ចបន្ទាប់ឯកឧត្តមអគ្គលេខាធិការ បានអនុញ្ញាតឱ្យប្រធាននាយកដ្ឋានចំនួន ០៣ រូប មកពីអគ្គនាយកដ្ឋានទាំង៣ រួមមាន៖ នាយកដ្ឋានស្រាវជ្រាវទូទៅ នាយកដ្ឋានព័ត៌មាន

និងនាយកដ្ឋានគ្រប់គ្រងបុគ្គលិក ឡើងរាយការណ៍អំពីលទ្ធផលការងារសម្រេចបានក្នុងខែមករា និងទិសដៅការងារខែកុម្ភៈជូនអង្គប្រជុំជ្រាប ។

បន្ទាប់ពីបានស្តាប់របាយការណ៍លទ្ធផលការងារសម្រេចបានក្នុងខែមករា និងទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២០ ឯកឧត្តមអគ្គលេខាធិការបានមានប្រសាសន៍ជម្រាបជូនអំពីព្រឹត្តិការណ៍ជាតិ-អន្តរជាតិសំខាន់ៗជូនដល់មន្ត្រីរាជការទាំងអស់ ដើម្បីជាមូលដ្ឋានក្នុងការបំពេញការងារឱ្យស្របតាមស្ថានភាពនៃការវិវឌ្ឍថ្មីៗនៃសភាពការណ៍ជាតិ និងអន្តរជាតិ ហើយក៏ជាចំណេះដឹងបន្ថែមសម្រាប់ការបំពេញការងារប្រចាំថ្ងៃផងដែរ។

## I. លទ្ធផលការងារសម្រេចបានក្នុងខែមករា ឆ្នាំ២០២០

### ១-មុខងារនីតិកម្ម

-ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន០២លើក និងប្រជុំពេញអង្គចំនួន០១លើក ដែលមានរបៀបវារៈដូចខាងក្រោម៖

១-របាយការណ៍ទូទាត់ថវិការបស់ព្រឹទ្ធសភាឆ្នាំ២០១៩

២-គោលការណ៍បែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០២០

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងសម្រាប់អនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ ទាក់ទងនឹងការគ្រប់គ្រង និងការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ហ្គ្រីន សឺស្តែនណេប៊ល វេនឈ័រ (ខេមបូឌា) ឯ.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គីសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព ២០ មេហ្គាវ៉ាត់ នៅខេត្តស្វាយរៀង

៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន រ៉ាយ ផៅវ័រ សឹបផ្លាយ ឯ.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គីសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព ៣០មេហ្គាវ៉ាត់ នៅខេត្តបន្ទាយមានជ័យ

៦-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន វ៉ាយសិន អេនើជី (ខេមបូឌា) បាត់ដំបង ៦.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព ៦០ មេហ្គាវ៉ាត់ នៅខេត្តបាត់ដំបង

៧-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ស្នេថេក អ៊ីនហ្វីនីត ៦.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព ៣០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់

៨-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ជីអេសប៊ីភី សេកុង ផៅវ័រ អ៊ែន មីនើរ៉ល ខមភេនី លីមីធីត នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

៩-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន សេកុង សឺមម័ល ផៅវ័រ ផ្លេន ខមភេនី លីមីធីត នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។

**២-មុខងារតំណាង**

-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន នៅសង្កាត់ព្រៃវែង ខណ្ឌដង្កោ និងខណ្ឌកំបូល រាជធានីភ្នំពេញ

-ឯកឧត្តម **ទេព ង៉ន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញជាអធិបតី និងចូលរួមពិធីផ្សេងៗរួមមាន៖

+វេទិកាថ្នាក់ខេត្តស្តីពី ការពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំថវិកា និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព នៅខេត្តមណ្ឌលគិរី

+ចែកសម្ភារសិក្សាជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅខេត្តរតនគិរី

+ពិធីក្រុងពាលីសុំសេចក្តីសុខសួស្តី ឱ្យដំណើរការរៀបចំបុណ្យខួបលើកទី៤១ នៃទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍៧មករា

-ឯកឧត្តមអនុប្រធានគណៈកម្មការទី៩ បានអញ្ជើញធ្វើបទបង្ហាញអំពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភាដល់សាស្ត្រាចារ្យ និងនិស្សិតនៃវិទ្យាស្ថានវ៉ាន់ដាគណនេយ្យ ចំនួន៥៣នាក់

-ក្រុមភូមិភាគទី៨ បានរៀបចំវេទិកាស្តីពី ការពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំថវិកា និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព នៅខេត្តមណ្ឌលគិរី

-សមាជិកព្រឹទ្ធសភា និងអគ្គលេខាធិការ តំណាងឱ្យសម្តេចប្រធានព្រឹទ្ធសភា បាន អញ្ជើញចុះសួរសុខទុក្ខ និងចូលរួមរំលែកទុក្ខ ព្រមទាំងឧបត្ថម្ភថវិកាដល់ក្រុមគ្រួសារសព កម្មករ ដែលជួបឧបទ្ទវហេតុបាក់រលំអគារ៧ជាន់ នៅខេត្តកែប

-សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសពលោកជំទាវ លី គីម ភរិយាឯកឧត្តម សោម ចិន សមាជិកគណៈកម្មការទី១០ នៃរដ្ឋសភា និងមហាឧបាសិកា តោ សេមគីម (តោ ឡេ) ត្រូវជាម្តាយបង្កើតឯកឧត្តមនាយសេនីយ៍ ឥត សារ៉ាត់ អគ្គមេបញ្ជាការរង និងជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ព្រៃវែង កែប កំពត ត្បូងឃ្មុំ កំពង់ចាម បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ មណ្ឌលគិរី និងខេត្តរតនគិរី។

**៣-មុខងារសហប្រតិបត្តិការអន្តរជាតិ**

-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា បានទទួលជួបសម្តែងការគួរសមជាមួយៈ

+ឯកឧត្តមប្រធានគណៈកម្មាធិការអេចិន្ត្រៃយ៍ ទទួលបន្ទុកកិច្ចការបរទេសនៃរដ្ឋសភា នៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស

+ឯកឧត្តមសមាជិករដ្ឋសភា និងជាប្រធានសម្ព័ន្ធមិត្តភាពសភាជប៉ុន-កម្ពុជា

+ឯកឧត្តមឯកអគ្គរដ្ឋទូតនៃសហរដ្ឋអាមេរិកប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-ឯកឧត្តមប្រធានគណៈកម្មការទី៣ និងជាប្រធានក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជា-កូរ៉េ បានអញ្ជើញទៅទស្សនកិច្ចការងារនៅប្រទេសកូរ៉េខាងត្បូង

-ឯកឧត្តមអគ្គលេខាធិការ បានអញ្ជើញចូលរួមប្រជុំគណៈកម្មាធិការអេចិន្ត្រៃយ៍នៃ សមាគមអគ្គលេខាធិការនៃសភាប្រើប្រាស់ភាសាបារាំង (ASGPF) នៅប្រទេសបារាំង

-ចូលរួមប្រជុំជាមួយរដ្ឋសភា ដើម្បីត្រៀមរៀបចំកិច្ចប្រជុំ ASEP នៅកម្ពុជា។

**៤-មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-ការធ្វើរបាយការណ៍ស្តីពីចំណូល-ចំណាយថវិកាព្រឹទ្ធសភា ឆ្នាំ២០១៩ និងការបែងចែកកញ្ចប់ថវិកាព្រឹទ្ធសភាឆ្នាំ២០២០ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-បន្តជួសជុលប្រព័ន្ធអគ្គិសនី ទឹក ជណ្តើរយន្ត ម៉ាស៊ីនត្រជាក់ ទ្វារ នៅសាលប្រជុំពេញអង្គ អគារក្រហម អគារDEF អគារជប៉ុន និងសាលពិសេសធំ...។ល។

-សាងសង់អគារថ្មីកម្ពស់២ជាន់នៅក្រោយអគារមូលនិធិខ្មែរអភិវឌ្ឍន៍

-ការងារបរិស្ថាន និងការដាំដើមឈើបន្ថែម ការងារសន្តិសុខ និងសណ្តាប់ធ្នាប់

-ការរៀបចំរចនាសម្ព័ន្ធ គោលការណ៍ និងគោលនយោបាយថ្មីៗ

-ប្រជុំផែនការការងារសម្រាប់ឆ្នាំ២០២០

-ប្រជុំស្តីពី ការរៀបចំកម្មវិធីសម្រង់មតិយោបល់លើសេចក្តីព្រាងច្បាប់របស់សមាជិកព្រឹទ្ធសភាតាម Online

-ប្រជុំស្តីពី ការគ្រប់គ្រងបណ្តាញសង្គមរបស់ព្រឹទ្ធសភា។

**៥-ការបណ្តុះបណ្តាលធនធានមនុស្ស**

-បានបើកវគ្គបណ្តុះបណ្តាលមន្ត្រីក្នុងប្រទេសចំនួន ០២វគ្គ មានសិក្ខាកាមចំនួន ៣៦នាក់

-បានទទួលដំណើរទស្សនកិច្ចសិក្សារបស់សាស្ត្រាចារ្យ និងនិស្សិតមកពីវិទ្យាស្ថានវ៉ាន់ដាគណនេយ្យចំនួន ៥៩នាក់

-ពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី ការវិភាគសារពើពន្ធ (FACT Program) ការិយាល័យថវិកាសភា (PBO) និងការទទួលយកមកវិញនូវមន្ត្រីដែលបានហ្វឹកហ្វឺនរួចហើយ ។

II. **ទិសដៅការងារសម្រាប់ខែកុម្ភៈ ឆ្នាំ២០២០**

**១-សេវាទ្រទ្រង់មុខងារនីតិកម្ម៖**

-ព្រឹទ្ធសភាវិស្សមកាលចាប់ពីថ្ងៃទី២៣ ខែមករា ដល់ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០។ តាមដានការប្រជុំវិសាមញ្ញព្រឹទ្ធសភា ។

**២-សេវាទ្រទ្រង់មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ**

-ត្រៀមសហការ និងសម្របសម្រួលការងារជូនគណៈកម្មការជំនាញជួបសវនាការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានារួមមាន៖

+គណៈកម្មការទី២ ចុះបេសកកម្ម ដើម្បីឈ្វេងយល់អំពី ការអភិវឌ្ឍប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងបុព្វបទថ្មី ពិសេសការងារចាត់ចែងការអនុវត្តថវិកា ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈ នៅខេត្តពោធិ៍សាត់

+គណៈកម្មការទី៣ ចុះបេសកកម្ម ទៅខេត្តកោះកុង

+គណៈកម្មការទី៩ ចុះបេសកកម្ម ដើម្បីផ្សព្វផ្សាយព័ត៌មាន និងច្បាប់អន្តោប្រវេសន៍ នៅខេត្តប៉ៃលិន បាត់ដំបង និងខេត្តពោធិ៍សាត់

+គណៈកម្មការទី១០ ចុះបេសកកម្ម ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានានៃការអនុវត្តច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការអភិវឌ្ឍមូលដ្ឋាន នៅខេត្តប៉ៃលិន និងខេត្តពោធិ៍សាត់

+ក្រុមភូមិភាគទី៥ ចុះស្រាវជ្រាវប្រមូលព័ត៌មានអំពីការប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តតាកែវ ។

**៣-សេវាទទួលទទួលមុខងារតំណាង៖**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមកម្មវិធីប្រជុំ និងពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗរួមមាន៖

+ក្រុមភូមិភាគទី២ រៀបចំវេទិកាថ្នាក់ស្រុក នៅស្រុកស្ទឹងត្រង់ និងស្រុកចំការលើ ខេត្តកំពង់ចាម

+ក្រុមភូមិភាគទី៤ សំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តឧត្តរមានជ័យ និងដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តបាត់ដំបង

-ត្រៀមពិធីបញ្ចុះខណ្ឌសីមាវត្ត នៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ។

**៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ៖**

-ត្រៀមរៀបចំពិធីជំនួបផ្លូវការរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូជាតិ និង អន្តរជាតិនានា ព្រមទាំងអគ្គទូតរួមមាន៖ ទូតគុយបា ទូតអូស្រ្តាលី ទូតអ៊ីស្រាអែល គណៈប្រតិភូជាន់ខ្ពស់ឡាវ

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ព្រមទាំងមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បំពេញបេសកកម្មក្រៅប្រទេស

-ត្រៀមរៀបចំទិវាហ្វ្រង់កូហ្វូនីប្រចាំឆ្នាំ (ខួបលើកទី៥០) នៅព្រឹទ្ធសភា (ថ្ងៃទី២០ ខែមីនា)

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា

-ការចូលរួមជាមួយរដ្ឋសភាដើម្បីរៀបចំ ASEP ឆ្នាំ២០២០។

**៥-ការអភិវឌ្ឍស្ថាប័ន**

-បង្កើនការគ្រប់គ្រងអគារ សារពើភ័ណ្ឌ និងការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃ ទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ INTERNET

-បន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅក្នុងព្រឹទ្ធសភា

-បន្តកែលម្អបរិស្ថាននៅក្នុងបរិវេណព្រឹទ្ធសភា

-រៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន គណៈកម្មការ និងក្រុមនានា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធី E បណ្ណាល័យ និង E បណ្ណសារ

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ ពីប្រកពប្រទេសផ្សេងៗទៀត (ឆ្នាំ២០២០)

-បន្តកសាង និងធ្វើបច្ចុប្បន្នភាពគោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តបម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ បង្កើនការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់វិស័យនៃការងាររបស់ស្ថាប័ន

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការផ្សេងៗ

-បន្តសហការជាមួយក្រុមការងារ (FMIS) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប្រើប្រាស់

-រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ICT អភិវឌ្ឍធនធានមនុស្ស ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ការស្រាវជ្រាវ និងសហប្រតិបត្តិការអន្តរជាតិ

-បន្តប្រជុំគណៈកម្មការគោលការណ៍ គោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-រៀបចំផែនការបណ្តុះបណ្តាលមន្ត្រីខ្សោយ និងពិបាកដោយផ្សារភ្ជាប់វិធានការណ៍ អប់រំ រដ្ឋបាល ច្បាប់ និងអភិក្រមទាំង៥

-បន្តរៀបចំក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងរយៈពេល១០ឆ្នាំទៅមុខ (ឆ្នាំ២០២១-ឆ្នាំ២០៣០)។ អគ្គនាយកដ្ឋានទាំង៣ ត្រូវផ្តល់ធាតុចូល មកអគ្គលេខាធិការដ្ឋានឱ្យបានត្រឹមបំណាច់ខែកុម្ភៈ ឆ្នាំ២០២០។

## III. សេចក្តីសន្និដ្ឋាន

ខែមករានេះ ជាខែដើមនៃឆ្នាំ២០២០ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានការងារមមាញឹកជាច្រើននៅគ្រប់ការដ្ឋាន ដើម្បីបញ្ចប់ការងារដែលនៅសេសសល់ពីឆ្នាំ២០១៩ ។ ម្យ៉ាងទៀត នេះជាជំហានដំបូងដើមឆ្នាំសម្រាប់អនុវត្តផែនការប្រតិបត្តិឆ្នាំ២០២០ តាមក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភា។ អគ្គលេខាធិការដ្ឋាន បានយកចិត្តទុកដាក់ខ្ពស់លើការកែសម្រួលសន្ទស្សន៍ប្រាក់បៀវត្សថ្មី និងអត្ថប្រយោជន៍បន្ថែមផ្សេងៗទៀតសម្រាប់មន្ត្រីរាជការ។ ដោយឡែក ការរៀបចំ និងចាត់ចែងការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា លើសេវាទ្រទ្រង់មុខងារនីតិកម្ម ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន ០១លើក បានយ៉ាងល្អប្រសើរ។ ចំពោះមុខងារតំណាង បានចុះរៀបចំវេទិកា និងអមដំណើរសមាជិកព្រឹទ្ធសភាចុះមូលដ្ឋាន ដើម្បីឈ្វេងយល់អំពីសុខទុក្ខ ដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានារបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។ ការអភិវឌ្ឍស្ថាប័ន តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន បានខិតខំជំរុញការផ្តល់សេវាឱ្យបានគាប់ប្រសើរ ហើយបន្តខិតខំកែលម្អសេវាទាំងឡាយ ដោយបង្កើនការប្រើប្រាស់តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាអតិបរមា ដើម្បីកាត់បន្ថយការប្រើប្រាស់ក្រដាស។ ទន្ទឹមនេះ បានពង្រឹងពង្រីកទំនាក់ទំនង

មិត្តភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ដោយរក្សាបាននូវភាពជាដៃគូជាមួយបណ្តាប្រទេស បណ្តាសភា និងដៃគូអភិវឌ្ឍន៍សំខាន់ៗជាច្រើនទៀត។

ការយកចិត្តទុកដាក់ពង្រឹងវិន័យ និងបន្តការបណ្តុះបណ្តាល គឺជាអាទិភាពសម្រាប់ដោះស្រាយចំពោះករណីមន្ត្រីខ្សោយ និងពិបាកដែលចាំបាច់ត្រូវប្រឈមដោះស្រាយដោយស្មារតីទទួលខុសត្រូវទាំងអស់គ្នា ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១.៣០នាទីព្រឹក ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាលប្រកបដោយស្មារតីទទួលខុសត្រូវ ។ល

ថ្ងៃចន្ទ ២ កើត ៥ ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០

ប្រធាននាយកដ្ឋាន

ឡាំង ថន

បានឃើញ និងឯកភាព

អគ្គលេខាធិការ

ឃុំ_សារីឧ

បានឃើញ និងឯកភាព

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ

ឈឹម ព្រះខ័ន